

# សេចក្ដីជំនឿ និងកិច្ចការ នៅក្នុងពិភពនៃផ្លូវលោក


## ប៊ីស្សព យេស៍ ប៊ី ម៉ាក់មូលីន

### ជាទីប្រឹក្សាទីពីរនៅក្នុងគណៈអធិបតីប៊ីស្សព


**ការប្រជុំ ស៊ី. អ៊ី. អេស. សំរាប់មជ្ឈឹមវ័យ • ថ្ងៃទី 5 ខែវិច្ឆិកា ឆ្នាំ 2006 • សាកលវិទ្យាល័យ ព្រីហ្គាំ យ៉ុង**

បងប្អូនប្រុសស្រី នេះជាទស្សនីយភាពដ៏គួរឱ្យកត់សំគាល់ដែលអ្នកកំពុងតែដើរមក ចេញពីដំណើរជីវិតផ្សេងៗ និងប្រទេសផ្សេងៗគ្នា។ ហើយនៅពេលល្ងាចនេះយើងបានប្រមូលផ្ដុំគ្នានៅទូទាំងផែនដី។ នៅចន្លោះពេលនេះ និងពេលធ្វើការចាក់ផ្សាយឡើងវិញ មជ្ឈឹមវ័យទូទាំងសាសនាចក្រនឹងប្រមូលផ្ដុំ ហើយចូលរួមជាមួយគ្នានៅក្នុងព្រឹត្តការណ៍ដូចនេះផងដែរ។ វាពិតជាអស្ចារ្យខ្លាំងណាស់។

រឿងរ៉ាវដ៏អស្ចារ្យបានកើតឡើងនៅក្នុងសន្និសីទទូទៅកាលពីខែមុន។ ចំពោះផ្នែកខ្លះនៃពិភពលោកមិនបានដឹងទេប៉ុន្តែចំពោះអស់អ្នកដែលស្គាល់ និងស្រឡាញ់សេចក្ដីពិត វាគឺជាសម្លេងមួយដ៏កងរំពងដែលមិនអាចបំភ្លេចបានរបស់មនុស្ស 10,000 នាក់។

ចូរគិតឡើងវិញអំពីសម័យប្រជុំបញ្ចប់។ ចេញពីក្រុមចំរៀងរោងឧបោសថមានទំនុកភ្លេងមួយដែលយើងធ្លាប់ឮ—

*យើងសូមអគុណព្រះអង្គចំពោះព្យាការី*
*ដែលដឹកនាំយើងក្នុងថ្ងៃចុងក្រោយនេះ។*
*យើងសូមអរគុណចំពោះព្រះសិក្ខាបទ*
*ដែលនឹងបំភ្លឺគំនិតចិត្តនៃយើង។* [1]

រំពេចនោះ ទាំងបុរសស្ត្រី និងក្មេងប្រុសស្រី បានជួបជុំគ្នានៅក្នុងមជ្ឈមណ្ឌលសន្និសីទបានក្រោកឡើងដោយការគោរព និងអំណរគុណចំពោះពរជ័យដែលបានរៀបរាប់នៅក្នុងទំនុកដំកើងនេះ។ យើងក្រោកឈរក្នុងអំណរគុណទទួលស្គាល់ថា ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទបានស្ដារឡើងវិញ ថាព្រះជាព្រះវរបិតា និងព្រះរាជបុត្រា សូនភ្វារបស់ទ្រង់បានមានព្រះបន្ទូលចេញពីស្ថានសួគ៌ថា យ៉ូសែប ស្ម៊ីធ គឺជាព្យាការី ហើយប្រធាន គរដុន ប៊ី ហ៊ីងឃ្លី គឺជាព្យាការីរបស់ព្រះនៅលើផែនដីបច្ចុប្បន្ននេះ។

វាគឺជាបទពិសោធន៍នៃការផ្លាស់ប្ដូរខាងវិញ្ញាណ។ វាគឺជាជំនាន់ដែលពលរដ្ឋទាំងអស់នៃនគររបស់ព្រះធ្វើកិច្ចការក្រោមឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធ *ក្រោកឈរឡើងដើម្បីសេចក្ដីជំនឿ!*

នៅព្រឹកនោះ ប្រធានហ៊ីងឃ្លី បានថ្លែងសុន្ទរកថាយ៉ាងទន់ភ្លន់ និងពោរពេញដោយអំណរគុណចំពោះវ័យដ៏ជឿនលឿនរបស់គាត់ និងអំពីសុខុមាលភាពរបស់គាត់។ គាត់មានប្រសាសន៍ថា តែងតែមានគំរូនៃសេចក្ដីស្មោះត្រង់ជានិច្ច គាត់បានសន្យាជីវិតថ្មីរបស់គាត់ចំពោះគោលបំណងរបស់ព្រះអម្ចាស់។

“ខ្ញុំអត់ដឹងថា ព្រះអម្ចាស់អនុញ្ញាតឱ្យខ្ញុំរស់នៅដល់ពេលណាទេ។ តែទោះដល់ពេលណាក៏ដោយ ក៏ខ្ញុំនឹងបន្តធ្វើឱ្យអស់ពីសមត្ថភាពចំពោះភារកិច្ចដ៏ចាំបាច់...។ តែយើងគួរតែអនុវត្តន៍តាមបំណងប្រាថ្នារបស់ព្រះ...។

“...យើងនឹងអអនុវត្តន៍ ដរាបណាព្រះអម្ចាស់មានបំណង...។
“ពេលណាដែលមានអ្នកទទួលតំណែងខ្ញុំបន្ត នោះការផ្លាស់ប្ដូរនឹងដំណើរការយ៉ាងរលូនស្របតាមឆន្ទៈរបស់ទ្រង់ ដែលជាម្ចាស់នៃសាសនាចក្រនេះ។ ហេតុដូច្នេះហើយយើងឆ្ពោះទៅមុខដោយសេចក្ដីជំនឿ— *ហើយសេចក្ដីជំនឿគឺជា ប្រធានបទដែលខ្ញុំចង់ពិភាក្សានៅព្រឹកនេះ។*” [2]

សារលិខិតរបស់គាត់គឺត្រូវតាមពេលវេលា និងមានការបំផុសគំនិត។ វាមកក្នុងនាមជាការរំលឹកខាងវិញ្ញាណថាតើជីវិត ពិតអំពីអ្វីទៅ និងពីរបៀបដែលកូនចៅរបស់ព្រះវរបិតាសួគ៌អាចយកឈ្នះលើរាល់គ្រប់ឧបសគ្គទាំងឡាយ។ វាមកនៅ ក្នុងពិភពលោកដែលមុជជ្រៅខាងលោកិយ ការឥតជំនឿ និងអំពើបាប។

## លទ្ធិដែលជឿអំពីសីលធម៌

ការអប់រំដែលមិនទាក់ទងទៅនឹងសាសនាស្ថិតក្រោមការបរិច្ចាគសំរាប់ភាពប្រសើរឡើងនៃពិភពលោករបស់យើង។ ការរៀនដែលមិនទាក់ទងទៅនឹងសាសនានៃកំរិតខ្ពស់បំផុតដែលរីកលូតលាស់នៅក្នុងបរិយាកាសនៃគុណធម៌ ការទទួលខុសត្រូវខាងចរិយាធម៌ សេចក្ដីពិតខាងវិញ្ញាណ និងសេចក្ដីជំនឿ។

បច្ចុប្បន្ននេះមនុស្សជាច្រើនត្រូវបានជ្រោតជ្រាបដោយសង្គមដែលមិនទាក់ទងទៅនឹងសាសនា។ មនុស្សនឹងពូជសាសន៍ទាំងអស់មានអំណួតយ៉ាងខ្លាំងចំពោះខ្លួនរបស់ពួកគេក្នុងការ *មិនទាក់ទងទៅនឹងសាសនា* “វត្ថុខាងលោកិយ ឬ [លើ ] វត្ថុដែលមិនចាត់ទុកថាជាខាងសាសនា ជាខាងវិញ្ញាណ ឬ ពិសិដ្ឋ។ ” [3]

មនុស្សជាច្រើនក្នុងពិភពលោកសព្វថ្ងៃនេះមើលឃើញលទ្ធិដែលជឿអំពីសីលធម៌ថាសំខាន់ដើម្បីមានតុល្យភាព យុត្តិធម៌ និងបានរៀបចំដោយរដ្ឋាភិបាល។ ហេតុនេះ ចំណាប់អារម្មណ៍ពីសាសនាគឺមិនត្រូវបានលើកទឹកចិត្តនៅក្នុងការពិភាក្សាជាសាធារណៈទេ សិទ្ធិស៊ីវិលគឺអាស្រ័យលើតុលាការ និងដំណើរការនីតិបញ្ញត្តិ ហើយបុរសស្ត្រីទាំងឡាយស្វែងរកដំណោះស្រាយរួចជាស្រេចហើយ ហើយទូរទាត់តាមរយៈមធ្យោបាយស្របច្បាប់ដែលសងដោយច្បាប់។ ហើយនៅទីបំផុតនោះ សង្គមលទ្ធិដែលជឿអំពីសីលធម៌ មើលរំលងពីគំនិតនៃជីវិតដ៏នៅអស់កល្បជានិច្ច ដាក់អ្វីៗទាំងអស់នៅក្នុងបរិបទនៃលោកិយធម្មតា ហេតុដូច្នេះហើយខ្លាចចំពោះ *កិច្ចការដោយគ្មានសេចក្ដីជំនឿ។*

វាតំរូវឱ្យមានការប្រយ័ត្នប្រយែង និងសេចក្ដីព្យាយាមយ៉ាងខ្លាំងដើម្បីធ្វើជាបុរស និងស្ត្រីនៃសេចក្ដីជំនឿនៅក្នុងពិភពលោកដែលមិនទាក់ទងទៅនឹងសាសនា...។ នៅពេលត្រូវជន់ដោយខាងលោកីយ៍ វាគឺជាធម្មជាតិរបស់មនុស្ស “ដំបូង ស៊ូទ្រាំ បន្ទាប់មកមានចិត្តអាណិតអាសូរ និងក្រោយមកទៀត និងក្រោយមកទៀតឱបក្រសោប។ លទ្ធិដែលជឿអំពីគុណធម៌គឺកំពុងជន់លិចមនុស្សនៅសព្វថ្ងៃនេះ ដែលបានស្ដែងឱ្យឃើញយ៉ាងច្រើន។



© 2006 ដោយ Intellectual Reserve, Inc។ រក្សាសិទ្ធិគ្រប់យ៉ាង។ បោះពុម្ពនៅព្រះរាជាណាចក្រកម្ពុជា។ អនុមតិជាភាសាអង់គ្លេសៈ 6/05។ 00942 258

មិនបានសង្កេតមើលដោយសេចក្តីជំនឿក្នុងព្រះគ្រីស្ទនៃព្រះអង្គប្រោសលោះនៃមនុស្សជាតិទាំងអស់ ការមិនទាក់ទងទៅនឹងសាសនា ឬ ពិភពលោកធម្មតានេះ ធ្វើឱ្យមានបុរស និងស្ត្រីដែល "មានអំនួត ខ្វល់តែពីខ្លួនឯង មានការប្រកួតប្រជែងហួសហេតុ ប្រឆាំងតបនឹងឥស្សរភាពដ៏ខ្លាំងក្លា ដឹកនាំដោយចំណង់ ការស្រេកឃ្លាន [ និង ] សេចក្តីប្រកាសរបស់លោកិយ...។ ជាទូទៅ និស្ស័យរបស់មនុស្សមិនអាចប្រោសលោះសត្វលោកបានឡើយដែលចាប់ផ្តើម ដើរ...នៅក្នុងពន្លឺភ្លើងរបស់ខ្លួនគាត់ផ្ទាល់។ [4] ...[សូមមើល នីហ្វៃទី 2 7:10–11] មនុស្សបែបនោះផ្លាស់ប្តូរនិស្ស័យធម្មជាតិរបស់គាត់យកពាក្យណែនាំរបស់គាត់ ហើយចាកចេញពីពិភពបរាជ័យរបស់គាត់...។ " [5] សេចក្តីថ្លែងដោយសង្ខេបយ៉ាងច្បាស់ថាៈ "មនុស្សនៅក្នុងស្ថានភាពធម្មជាតិ...គ្មានព្រះទេនៅក្នុងលោកនេះ" (អាលម៉ា 41:11)។

ពីព្រោះលទ្ធិដែលជឿអំពីសីលធម៌ ជាទូទៅមិនយកចិត្តទុកដាក់ភាពអស់កល្បជានិច្ច នោះពេលខ្លះវាអាចដឹកនាំទៅរកភាពមិនជឿ។ ពាក្យសំដីរបស់ រ៉ូលហាត ផេនីស្បើច ជាសាស្ត្រផ្នែកសាសនាវិទ្យានៅសាកលវិទ្យាល័យតន្ត្រី បាននិយាយថាៈ

"បរិយាកាសសាធារណៈនៃលទ្ធិដែលជឿអំពីសីលធម៌ទំលាយចោលការទុកចិត្ត នៃពួកគ្រីស្ទាន ចំពោះសេចក្តីពិតនៃអ្វីដែលពួកគេជឿ...។

"បរិយាកាសក្នុងការមិនទាក់ទងទៅនឹងសាសនា សូម្បីតែចំណេះដឹងជាបឋមនៃគ្រីស្ទាន...ក៏ថយចុះបន្តិចម្តងៗ។ វាមិនមែនជាបញ្ហាទៀតទេក្នុងការបដិសេធន៍ការបង្រៀនរបស់គ្រីស្ទាន មនុស្សជាច្រើនមិនមានចំណេះដឹង ស្រពិចស្រពិលពីការបង្រៀនទាំងនោះ...។ កាន់តែផ្សព្វផ្សាយកាន់តែមានការមិនខ្វល់ខ្វាយចំពោះពួកគ្រីស្ទានកាន់តែមានការប្រកាន់សាសន៍ ប្រឆាំងនឹងគ្រីស្ទានកាន់តែខ្លាំងឡើង...។

"...ការលំបាកក៏កាន់តែធ្ងន់ធ្ងរឡើង តាមរយៈការបណ្តុះវប្បធម៌ដែលទាក់ទងគំនិតផ្សេងគ្នាពីសេចក្តីពិត...។ ទៅតាមទស្សនៈជាច្រើន...គោលលទ្ធិនៃគ្រីស្ទានគ្រាន់តែជាមតិដែលប្រហែលជាអាច ឬមិនអាចបញ្ជាក់អះអាង ស្របទៅតាមចំណូលចិត្តរបស់បុគ្គលម្នាក់ៗ ឬ អាស្រ័យទៅលើថាតើ ពួកគេនិយាយពីអ្វីដែលពួកគេមានអារម្មណ៍ថា ចាំបាច់ផ្ទាល់ខ្លួន...។

"...សង្គមដែលមិនទាក់ទងទៅនឹងសាសនា ធ្វើឱ្យមានអារម្មណ៍នៃការគ្មានខ្លឹមសារ។" [6]

សេចក្តីជំនឿលើព្រះគ្រីស្ទជំនួសដោយសេចក្តីជំនឿលើមនុស្ស។ ការពិភាក្សាជាសាធារណៈ ឬ ផ្ទាល់ខ្លួនពីសំណួរថាតើ យើងមកពីណា តើយើងទៅទីណាក្រោយជីវិតនេះ ហើយនៅទីបំផុតតើអ្វីជាអ្នកគ្រប់គ្រងជីវិតនៅលើផែនដីនេះមិនមែនត្រឹមតែមិនអាចរកពាក្យអ្វីថ្លែងបាននោះទេ ប៉ុន្តែបានចាត់ថាមិនទាក់ទងគ្នាផងដែរ។ នេះគឺជាសណ្ឋានរបស់មនុស្សដែលមិនជឿ ហើយប្រែក្លាយទៅជាសោកនាដកម្មមួយដ៏ធំ។

ព្រះវរបិតាសួគ៌ដឹងថារឿងនេះនឹងកើតឡើង។ ការស្តារឡើងវិញនៃដំណឹងល្អបានធ្វើឱ្យសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ ដែលជាព្រះអង្គបង្កបង្កើត ព្រះអង្គសង្គ្រោះ និងព្រះប្រោសលោះឱ្យកើតមានឡើងវិញ។ វាបាននាំមកនូវចំណេះដឹងត្រឹមត្រូវពីគោលបំណងរបស់ជីវិតនេះ។ នៅក្នុងឆ្នាំ 1831 កូនចៅព្រះវរបិតាសួគ៌ត្រូវបានប្រាប់ថាៈ

"ហេតុដូច្នេះហើយ យើងជាព្រះអម្ចាស់ ដោយជ្រាបនូវគ្រោះដែលនឹងមានមកលើបណ្តាជនទាំងឡាយនៅលើផែនដីនេះ នោះបានហៅ យ៉ូសែប ស្ម៊ីធ ជុញ្ញ័រ...ហើយបាននិយាយមកកាន់លោកពីលើស្ថានសួគ៌ហើយបានប្រទានបញ្ញត្តិទាំងឡាយដល់លោក...

"ថាសេចក្តីជំនឿ...អាចបានកើនឡើងនៅលើផែនដី...។" (គ និង ស 1:17, 21)។

មុនពេលគ្រឹះនៃពិភពលោកនេះបានស្ថាបនាឡើង ពីមុនគន្លងនៃសកលលោកបានទទួលកន្លែងរបស់វា បុរស និងស្ត្រីទាំងឡាយមានជីវិត ចលនា ហើយមានរូបសណ្ឋានរបស់ពួកគេ។ (សូមមើល កិច្ចការពួកសាវក 17:28)។ មនុស្សដែលមិន ជឿលើអទិទេពមានគំនិតថា ជីវិតនេះ គឺគ្មានអ្វីច្រើនជាងការយល់ទៅលើជីវសាស្ត្រ បដិសេធន៍មូលដ្ឋានគ្រឹះនៃសេចក្តពិតដែលគ្មានសតិសម្បជញ្ញៈដឹងថាកំពុងរស់នៅទីរហោស្ថាននៃព្រលឹងទាំងឡាយដែលកំពុងមានជីវិតថា "មនុស្សក៏ *បាន* រស់នៅជា*មួយនឹងព្រះដែរ* ។ " (គ និង ស 93:29 អក្សរទ្រេតជាការបន្ថែម)។ កត្តានេះមិនផ្លាស់ប្តូរ និងមិនអាចបដិសេធន៍បានឡើយ។

ឪពុកម្តាយដំបូងរបស់យើងគឺអ័រដាម និងអេវ៉ា បាននៅកន្លែងបរមសុខនៅអេដែន ដើម្បីមនុស្ស តាមរយៈបទពិសោធន៍ នៃជីវិតរមែងស្លាប់ និងការប្រោសលោះរបស់ព្រះគ្រីស្ទអាចប្រែក្លាយទៅជាមានលក្ខណៈពេញលេញ និងរូបកាយល្អឥតខ្ចោះ។ អាយុកាលនៃលោកអយ្យកោ ការយាងមកពីទីខ្ពស់នៃព្រះអង្គសង្គ្រោះរបស់យើង និងជង្ហាយធ្ងនដ៏មិនអាចប្រៀបផ្ទឹមបាននៅពាក់កណ្តាលយុគសម័យ ហើយ "ជរាបដល់គ្រាតាំងរបស់ទាំងអស់ឡើងវិញ" (កិច្ចការពួកសាវ 3:21) ដែលបានចាប់ផ្តើមឡើងក្នុងឆ្នាំ 1820 ដែលបានរៀបចំគម្រោងឡើងដោយបុរសស្ត្រី ក្មេងប្រុសស្រីឱ្យ អាចគ្រប់គ្រងជីវិតរបស់ពួកគេ ហើយឡោមពទ្ធ័ដោយ "សេចក្តីជំនឿជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ " (មាត្រានៃសេចក្តីជំនឿ 1:4)។

មិត្តវ័យក្មេងទាំងឡាយជាទីស្រឡាញ់របស់ខ្ញុំ អ្នកឈរនៅលើចំណុចប្រសព្វ នៅលើព្រឹត្តិការណ៍ទាំងនោះក្នុងពិភពលោក។ "តើព្រឹត្តិការណ៍អ្វីដែលបាននាំមុខនៅអតីតកាល ហើយតើព្រឹត្តិការណ៍អ្វីដែលមិនទាន់កើតឡើងនៅឡើយ។ " [7] តើអ្វីអាចកើតឡើង—តើអ្វីត្រូវតែកើតឡើង—នោះជាសេចក្តីជំនឿ និងការចូលរួមនៅក្នុងកិច្ចការនឹងបញ្ឈប់ការលូតឡើងនៃការមិនជឿឬទេ។ នេះគឺជាជោគវាសនារបស់អ្នកនៅក្នុងជីវិត។ នេះគឺជាករណីកិច្ចដ៏ពិសិដ្ឋរបស់អ្នក។

## បទដ្ឋាននៃសេចក្តីជំនឿ

លោកគ្រូរបស់យើងមានបន្ទូលថា "បើមានសេចក្តីជំនឿដូចគ្រាប់ពូជមួយយ៉ាងល្អិត...ក៏គ្មានការអ្វីដែលអ្នករាល់គ្នាធ្វើមិនកើតនោះទេ។ " (ម៉ាថាយ 17:20 )។ ប្រធាន ប្រធាន ហ៊ីងឃ្លី បានរំលឹកយើងថាៈ

"ពេលដែលអ្វីៗបាននិយាយ និងធ្វើរួចហើយ នោះទ្រព្យសម្បត្តិតែមួយគត់របស់សាសនាចក្រគឺ សេចក្តីជំនឿរបស់សមាជិក។ [8]

"នៅក្នុងការឈានជើងទៅមុខក្នុងបព្វហេតុដ៏អស្ចារ្យនេះ នោះសេចក្តីជំនឿបានកើនឡើង គឺជាអ្វីដែលយើងទាំងអស់គ្នាត្រូវការជាចាំបាច់។ បើគ្មានជំនឿទេ កិច្ចការនឹងនៅមួយកន្លែង។ បើមានវិញគ្មាននរណាម្នាក់អាចបញ្ឈប់ការរីកចំរើនរបស់វាបានឡើយ។"[9]

សេចក្តីជំនឿគឺមិនគ្រាន់តែជាឥរិយាបទ ជាការជឿ ជាទីបន្ទាល់ ការដឹង ឬអារម្មណ៍របស់មនុស្សម្នាក់ប៉ុណ្ណោះទេ។ សេចក្តីជំនឿពិត គឺជំនឿដែលបានមានប្រសាសន៍ដោយព្យាការីជាទីស្រឡាញ់របស់យើង ដែលបានផ្តល់ឱ្យនូវភាពសុចរិតនៅក្នុងជីវិតនេះ និងសេចក្តីសង្គ្រោះក្នុងជីវិតក្រោយទៀត។ វាមានចំណុចសំខាន់ស្ថិតនៅលើសេចក្តីពិត លើ



© 2006 ដោយ Intellectual Reserve, Inc។ រក្សាសិទ្ធិគ្រប់យ៉ាង។ បោះពុម្ពនៅព្រះរាជាណាចក្រកម្ពុជា។ អនុមតិជាភាសាអង់គ្លេសៈ 6/05។ 00942 258

ព្រះដែលមានព្រះជន្ម និងលើព្រះយេស៊ូវគ្រីស្ទ ដែលទ្រង់បានបញ្ជូនមក (សូមមើល យ៉ូហាន 17:3 )។ វាគឺជាមូលដ្ឋានគ្រឹះលើសេចក្តីពិតមកដល់មុនចំណេះដឹង ហើយបានឥតខ្ចោះតាមរយៈការអនុវត្ត។ វាជាបុព្វហេតុមួយដែលធ្វើឱ្យជីវិតរមែងស្លាប់នេះ យល់ ហើយប្រព្រឹត្តិទៅតាមអ្វីដែលកូនចៅរបស់ព្រះវរបិតាសួគ៌គួរតែធ្វើគឺ " សេចក្តីជំនឿ..." គឺជាគោលការណ៍គ្រប់គ្រងទីមួយដ៏មហិមា ដែល... [ធ្វើឱ្យយើងមាន] ព្រះចេស្តាមានអំណាច និងសិទ្ធិអំណាចលើ " [10] អ្វីដែលយើងគិត អ្វីដែលយើងធ្វើ ហើយតើយើងជាបុរសស្ត្រីត្រូវមានឥរិយាបទបែបណា។

សាវក យ៉ាកុប បានផ្តល់ទំរង់បែបបទពីសេចក្តីជំនឿថាៈ

"តើមានប្រយោជន៍អ្វី...។ បើមនុស្សម្នាក់និយាយថាគាត់មានជំនឿ ប៉ុន្តែមិនប្រព្រឹត្តតាម...?

"មែនហើយ បើមនុស្សម្នាក់និយាយថា ខ្ញុំនឹងបង្ហាញទ្រង់ថា ខ្ញុំមានសេចក្តីជំនឿតែមិនប្រព្រឹត្តតាម តែខ្ញុំនិយាយថា ចូរបង្ហាញសេចក្តីជំនឿតែមិនប្រព្រឹត្តតាមរបស់អ្នក ហើយខ្ញុំនឹងបង្ហាញសេចក្តីជំនឿរបស់ខ្ញុំដល់ទ្រង់តាមរយៈការប្រព្រឹត្តតាម...

"...សេចក្តីជំនឿ តែម្យ៉ាងបើគ្មានការអនុវត្តទេ នឹងស្លាប់...

"មើលចុះ...តើសេចក្តីជំនឿជាមួយការប្រព្រឹត្ត...តាមធ្វើឱ្យសេចក្តីជំនឿបានល្អឥតខ្ចោះឬ?" (JST យ៉ាកុប 2:14–15, 17, 21)។

យើងបានឮច្រើនមកហើយអំពី *ចំណុចគោល*។ ចំណុចគោលគឺជា "បទដ្ឋានដ៏ឧត្តុងឧត្តម [ឬ] ជោគជ័យប្រឆាំងនឹងវត្ថុដែលស្រដៀងគ្នានេះ [គឺជា] រង្វាស់ ឬការវិនិច្ឆ័យ។ " [11]

មានចំណុចគោលបួន ដែលអាចជួយឱ្យយើងម្នាក់ៗដឹងថា សេចក្តីជំនឿលើព្រះគ្រីស្ទ ចាប់ផ្តើម "ធ្វើឱ្យល្អឥតខ្ចោះ" តាមរយៈការប្រព្រឹត្តតាមរបស់យើង។ ចំណុចគោលទាំងនេះមានៈ (1) ការជ្រើសរើសដែលយើងធ្វើ (2) ជំនឿស៊ប់ដែលយើងសម្តែងឱ្យឃើញ (3) ការគោរពដែលយើងអនុវត្តន៍ ហើយ (4) ការបំរើដែលយើងផ្តល់ឱ្យ។ ខ្ញុំសូមអនុញ្ញាតធ្វើការពន្យល់។

## ការជ្រើសរើសដែលយើងធ្វើ

*ទីមួយ ចំណុចគោលនៃការជ្រើសរើស។* ពួកបរិសុទ្ធថ្ងៃចុងក្រោយ—"ជឿលើ *ភាព*ទៀងត្រង់ ត្រឹមត្រូវ បរិសុទ្ធ គុណធម៌...។ បើសិនជាមានអ្វីណាមួយដែលប្រកបដោយគុណមធម៌ គួរឱ្យស្រលាញ់ ឬ ឈ្មោះល្អ ឬ ក៏គួរឱ្យសរសើរ នោះយើង *យើងស្វែងរក*របស់ផងទាំងនេះហើយ។" (មាត្រានៃសេចក្តីជំនឿ 1:13 អក្សរទ្រេតជាការបន្ថែម)។

ចូរគិតស្រមៃ ពីអែលឌើរវ័យក្មេងម្នាក់ ដែលមានឈ្មោះថា បៀល។ គាត់បានរៀនពីអ្វីទាំងអស់នេះក្នុងថ្នាក់កុមារ។ គាត់បានជឿតាំងពីពេលនោះមក មកដល់ពេលនេះគាត់នៅតែជឿ ទោះជាយ៉ាងនេះក្តី បៀល បានទទួលការរុកគួនដោយរូបអាសអាភាស។ យើងរកឃើញថាវាធ្វើឱ្យគាត់ស្រើបស្រាល និងញៀន។ បន្ទាប់ពីជួបប្រទះរឿងស្មោកគ្រោកនេះមក បៀល មានអារម្មណ៍ថា គួរឱ្យស្អប់ខ្ពើម អាម៉ាស់ និងគ្មានភាពសក្តិសមក្នុងខ្លួន។

បៀល បានចូលរួមនៅក្នុងសន្និសីទទូទៅ ពីរបីសប្តាហ៍កន្លងទៅនេះ។ នៅក្នុងសម័យប្រជុំបព្វជិតភាព គាត់បានឮ ប្រធាន ហ៊ីងឃ្លី មានប្រសាសន៍ថា ៈ

"គ្មានបុរស ឬក្មេងប្រុសណាម្នាក់ នៅក្នុងសាលាប្រជុំដ៏ធំនេះមិនអាចអភិវឌ្ឍន៍ជីវិតរបស់គាត់ឡើយ។ ហើយរឿងនេះត្រូវតែកើតឡើង។ ព្រោះយើងទាំងអស់គ្នា គឺជាអ្នកកាន់បព្វជិតភាពរបស់ព្រះ...។

"ដោយសារបព្វជិតភាពទើបធ្វើឱ្យយើងមានកាតព្វកិច្ចដ៏ធំ ក្នុងការមានភាពសក្តិសម។ យើងមិនត្រូវឱ្យភាពមិនស្អាតស្អំ ចូលក្នុងគំនិតឡើយ។ យើងមិនត្រូវមើលរូបអាសអាភាសឡើយ។ យើងមិនត្រូវធ្វើឱ្យមានវិប្បដិសារីនៃអំពើរលោភបំពានក្នុងគ្រប់រូបភាព។ យើងត្រូវយកឈ្នះលើរឿងទាំងអស់នេះ។ ' ចូរក្រោកឡើងបុរសទាំងឡាយនៃព្រះ! ' ចូរលះបង់រឿងទាំងនោះចោល នោះព្រះអម្ចាស់នឹងដឹកនាំ និងគាំទ្រអ្នក។ " [12]

បៀល បានសំរេចចិត្តថាៈ *"ដល់ពេលដែលខ្ញុំត្រូវក្រោកឈរឡើង ដើម្បីសេចក្តីជំនឿរបស់ខ្ញុំហើយ!"*

គាត់បានទៅកន្លែងសម្ងាត់ យករូបស្មោកគ្រោក កាសែតអាក្រាត និងអក្សរសរសេរអសុរសទាំងឡាយ ហើយបំផ្លាញចោល។ គាត់បានបោសសំអាតបណ្ណាល័យរបស់គាត់យ៉ាងស្អាតបំផុត តន្ត្រីខ្លាំងៗ និងទំនុកស្មោកគ្រោកទាំងឡាយ។ គាត់បានលុបចេញពីកុំព្យូទ័ររបស់គាត់ពីកម្មវិធីទាំងឡាយដែលទាក់ទងនឹងរូបអាសអាភាស បញ្ចូលអ្វីដែលមានប្រយោជន៍ហើយដាក់កុំព្យូទ័ររបស់គាត់នៅកន្លែងសាធារណៈ ដើម្បីជួយឱ្យខ្លួនគាត់រឹងមាំប្រឆាំងនឹងអំពើបាបដែលកើតឡើងដដែលៗ។

បៀល ដឹងថាគាត់បានធ្វើអំពើរំលងចំពោះព្រះភក្រ័ព្រះ។ គាត់បានអធិស្ឋានដោយគារវភាព សុំភាពរឹងមាំដើម្បីធ្វើការប្រែចិត្ត ដើម្បីបណ្តេញអំពើអាក្រក់ចេញពីជីវិតរបស់គាត់។ គាត់បានស្វែងរកជំនួយពីប៊ីស្សពរបស់គាត់ និងមនុស្ស ដែលគាត់ស្រឡាញ់។ នៅទីបំផុតនោះ បៀល មានអារម្មណ៍ស្ងប់ស្ងាត់មកបញ្ជាក់ថា "កូនប្រុស កូននៅលើផ្លូវត្រូវហើយ។" សេចក្តីជំនឿរបស់គាត់មានការអនុវត្តតាម ចាប់ផ្តើមវិវដ្ឍមាន និងរឹងមាំ។

អ្វីដែលត្រូវធ្វើបន្តទៀតនោះ។ ត្រូវតែតមអាហារ អធិស្ឋាន សិក្សាព្រះគម្ពីរ និងបង្ហូរទឹកភ្នែកជាច្រើន។ ប៊ីស្សពល្អនឹងផ្តល់ជំនួយសំខាន់ៗដើម្បីជួយ។ ដោយសារការអធិស្ឋានស្មោះត្រង់របស់ឪពុកម្តាយ និងមនុស្សដែលគេស្រឡាញ់ និងផ្តល់នូវសេចក្តីត្រូវការចាំបាច់។ *ទោះជាយ៉ាងណាក៏ដោយចំណុចគោលបង្ហាញថាៈ បៀល ចាប់ផ្តើមអនុវត្តន៍សេចក្តីជំនឿ ដោយការប្រែចិត្ត—គាត់បានធ្វើការជ្រើសរើសត្រូវហើយ!*

## ការប្រជុំធម្មនិដ្ឋានដែលយើងបង្ហាញ

*ទីពីរ បទដ្ឋានការប្រជុំធម្មនិដ្ឋាន។* ពួកបរិសុទ្ធថ្ងៃចុងក្រោយ "ជឿចំពោះការណ៍ទាំងអស់ដែលទ្រង់បានបើកសម្តែងមក និងការណ៍ទាំងអស់ ដែលទ្រង់បើកសម្តែងនៅពេលឥឡូវនេះ ហើយយើងខ្ញុំជឿថា ទ្រង់នឹងបើកសម្តែងនូវការណ៍ដ៏ធំ និង សំខាន់ៗជាច្រើន ដែលទាក់ទងនឹងនគរនៃព្រះ។

"យើងខ្ញុំជឿចំពោះការប្រមូលដ៏ពិតប្រាកដនៃសាសន៍អ៊ីស្រាអែល និងចំពោះការសាងឡើងវិញ នូវពូជទាំងដប់អំបូរ ថាក្រុងស៊ីយ៉ូន (ក្រុងយេរូសាឡិមថ្មី) នឹងត្រូវបានស្ថាបនានៅលើទ្វីបអាមេរិក " (មាត្រានៃសេចក្តី ជំនឿ 1:9–10) ហើយបុរសស្ត្រីទាំងឡាយគឺ "បានហៅដោយការព្យាករ" និងសិទ្ធិអំណាចអទិទេព ដើម្បីធ្វើឱ្យកិច្ចការនេះបានសំរេច (មាត្រានៃសេចក្តីជំនឿ 1:5 )។



© 2006 ដោយ Intellectual Reserve, Inc។ រក្សាសិទ្ធិគ្រប់យ៉ាង។ បោះពុម្ពនៅព្រះរាជាណាចក្រកម្ពុជា។ អនុមតិជាភាសាអង់គ្លេសៈ 6/05។ 00942 258

ជំនឿស៊ប់ពិតប្រាកដគឺត្រូវបានចងភ្ជាប់នឹងបព្វហេតុដែលបានរៀបចំតាំងពីមុនការស្ថាបនៃពិភពលោកនេះ។ ជីដូនជីតា សុចរិតមានចំណែកនៅជាមួយពួកគេ ហើយផ្ដល់ដល់ជីវិតគេនូវការរីកចំរើនទៅមុខទៅរកគោលបំណងរបស់ព្រះវរបិតាសួគ៌។ យើងត្រូវបានប្រគល់ឱ្យដើម្បីយកវាមកជាមួយ ដើម្បីស្ថាបនានៅលើកិច្ចការឧទ្ទិសថ្វាយរបស់ពួកគេ។

ឥឡូវមានរឿងមួយ ដែលជារឿងស្រដៀងគ្នាទៅនឹងអ្នករាល់គ្នាមួយចំនួន។

នៅក្នុងឆ្នាំ 1856 រ៉ូប៊ីត និងអាន ផាកគី ជាមួយនឹងកូនបួននាក់របស់ពួកគេបានចុះពីនាវាមកពីប្រទេសអង់គ្លេស ចូលរួមជាមួយពួកបរិសុទ្ធនៅ យូថាហ៍។ ព្យាការីបានមានប្រសាសន៍ថា ហើយវាជាភារៈរបស់ពួកគេក្នុងការប្រមូលគ្នាទៅ ហ្វ្រេគ បាស៊ីន ហើយជួយគ្នាកសាងស៊ីយ៉ូន។ ក្នុងនាមជាសមាជិករបសក្រុមរទេះរុញ មិុកអ័រស៊ើរ មនុស្សម្នាក់ៗនៅក្នុងគ្រួសាររបស់ពួកគេមានភារកិច្ចចែកចាយបន្ទុកនៃកិច្ចការងារ។ ឪពុកម្ដាយ ទាញរទេះដ៏ធ្ងន់ ម៉ាស៊ីន (អាយុ 12 ឆ្នាំ) រុញ ហើយ ម៉ាថា (អាយុ 10 ឆ្នាំ) មើលប្អូនតូច អ័រស៊ី (អាយុ 5 ឆ្នាំ)។ អាដា (អាយុ 1 ឆ្នាំ)ដែលទើបចេះដើរតេះតាស់ ត្រូវបានពរ និងដាក់ឱ្យជិះនៅលើរទេះរុញ។

នៅ ទីប្រាសស្ការ ប្អូនតូច អ័រស៊ីបានអង្គុយចុះសំរាក ហើយក៏បានដេកលក់។ រំពេចនោះមានខ្យល់ព្យុះដ៏ធំ។ ក្រុមរទេះរុញទាំងអស់ប្រញាប់ប្រញាល់បោះជំរុំ។ ហើយបន្ទាប់មកទើបពួកគេដឹងថា អ័រស៊ី មិនបាននៅជាមួយក្មេងដទៃទៀតទេ។

ជាច្រើនថ្ងៃខំស្វែងរកមិនបានការ។ ក្រុមរទេះត្រូវតែធ្វើដំណើរទៅមុខ។ នោះគឺជាពេលដែល រ៉ូប៊ីត និងអាន ផាកគី ត្រូវតែអនុវត្តន៍ទៅតាមសេចក្ដីជំនឿរបស់ពួកគេ។ អ័រឆីវលធី បានកត់ក្នុងកំណត់ហេតុប្រចាំថ្ងៃថា នៅថ្ងៃទី 2 ខែកក្កដា ឆ្នាំ 1856 ថាៈ “កូនប្រុសតូច បងប្រុស ផាកគី...បានវង្វេង ហើយឪពុកបានត្រឡប់ទៅរកគាត់វិញ។ ”

ខណះដែល រ៉ូប៊ីត ចេញទៅ អាន បានខ្ចាស់ក្រម៉ារុំកពណ៌ក្រហមឆ្អៅលើស្មារបស់គាត់ ហើយនិយាយថាៈ “បើរកឃើញសាកសពគាត់ ចូររុំគាត់នឹងក្រម៉ារុំកហើយកប់គាត់។ បើគាត់នៅរស់ ចូរប្រើក្រណាត់នេះជាសញ្ញានៃទង់ជ័យដល់យើង។” នាង និងកូនៗផ្សេងទៀត បានលើករទេះឡើង ហើយខំពុះពារធ្វើដំណើរទៅជាមួយក្រុមរទេះរុញ។

រ៉ូប៊ីត ដើរតាមដានដើងចាស់ចូលទៅក្នុងព្រៃ ស្រែកហៅ រុករក ហើយអធិស្ឋាន សូមជំនួយដល់កូនប្រុសតូចដែល គ្មានគោលដៅ។ យ៉ាងតិចណាស់គាត់ធ្វើដំណើរមួយម៉ែលទៅកន្លែងចាស់ ទើបគាត់ដឹងថាកូនប្រុសរបស់គាត់ត្រូវបាន អ្នកកាប់អុស និងភរិយារបស់គាត់រើសបាន។ កូនប្រុសតូចរបស់គាត់បានឈឺ ដោយការផ្លាស់ប្ដូរអាកាសធាតុ និងការភិតភ័យ [ប៉ុន្តែ ] ព្រះបានឮការអធិស្ឋានរបស់រាស្ត្រទ្រង់។

នៅតាមផ្លូវរាល់យប់ អាន និងកូនៗរបស់គាត់ទន្ទឹងរង់ចាំមើលផ្លូវ។ នៅយប់ទីបី ខណៈពេលដែលពន្លឺព្រះអាទិត្យចាបផ្ដើមលិចប៉ះពន្លឺព្រិលៗនៃក្រម៉ាបង់កពណ៌ក្រហម ម្ដាយដ៏ក្លាហាននេះបានចុះក្នុងទឹកពូនពំនូកខ្សាច់ទាំងគួរឱ្យអាណិត។ អស់ពីកំលាំងកាយចិត្តគឺជាពេលដែលអានដេកលក់លើកទីមួយក្នុងរយៈពេលប្រាំមួយយប់ប្រាំមួយថ្ងៃ។ [13] ព្រះអម្ចាស់មានព្រះទ័យល្អ និងសប្បុរសយ៉ាងជ្រាលជ្រៅ ការប្រព្រឹត្តតាមរបស់ពួកគេបានទទួលរង្វាន់ដោយសារជំនឿស៊ប់ និងសេចក្ដីជំនឿដ៏បរិសុទ្ធ ហើយដោយក្ដីអំណរយ៉ាងខ្លាំងចេញពីដួងចិត្តពួកបរិសុទ្ធបានច្រៀងថា “ស្រួលទាំងអស់!” [14]

ក្មេងតូច អាដា ដែលបច្ចុប្បន្ននេះជាជីដូនរបស់ខ្ញុំ បានធំឡើងជាស្ត្រីពេញវ័យ ហើយរៀបការជាមួយជីតារបស់ខ្ញុំ ព្រីហ្គាំ យ៉ឹង ម៉ាក់មូលីន។ ឥឡូវនេះគឺជាសីលធម៌។ គាត់មិនដែលឱ្យកូនរបស់គាត់បំភ្លេចថា គាត់នឹងក្រុមគ្រួសារ បានធ្វើដំណើរឆ្លងកាត់ទីវាលជាមួយដាញ៉ែល ឌី មិកអ័រស៊ើ ជាមួយក្រុមរទេះរុញឡើយ។ រឿងរ៉ាវក្រម៉ាបង់កពណ៌ក្រហមប្រែក្លាយទៅជារឿងរបស់យើង—កេរ្ដិ៍ដំណែលនៃសេចក្ដីជំនឿរបស់ពួកគាត់ក្លាយជាជំនឿរបស់យើងដូចគ្នា។ ហេតុដូច្នេះហើយ យើងត្រូវតែ “ប្រកាន់ខ្ជាប់” [15] ហើយឧបសគ្គដ៏ធំបានសាបរលាប ដូចជាដំណក់សន្សើមនៅចំពោះព្រះអាទិត្យ។

រឿងអំពីពួកបរិសុទ្ធជំនាន់មុនជា *ចំណុចគោលដែលបង្ហាញថាៈ ការប្រព្រឹត្តតាមរបស់ពួកគេគឺជាសញ្ញាសំគាល់ នៃសេចក្ដីជំនឿ ជំនឿស៊ប់របស់ពួកគេ គឺជាបទដ្ឋាន សំរាប់កូនចៅជំនាន់ក្រោយរបស់គេរស់នៅតាម។*

## ការគោរពប្រតិបត្តិដែលយើងធ្វើតាម

*ទីបី បទដ្ឋាននៃការប្រតិបត្តិ។* ពួកបរិសុទ្ធថ្ងៃចុងក្រោយ “ជឿថាតាមរយៈដង្វាយធួននៃព្រះគ្រីស្ទ នោះមនុស្ស លោកទាំងអស់បានសង្គ្រោះ ដោយសារការ *គោរពប្រតិបត្តិតាមក្រិត្យវិន័យ និងពិធីការទាំងឡាយនៃដំណឹងល្អ* ” (មាត្រានៃសេចក្ដីជំនឿ 1:3 អក្សរទ្រេតគឺជាការបន្ថែម)។

យើងស្រមៃមើលពីគូស្វាមីភរិយាវ័យក្មេងមួយគូ ដែលជាតំណាងនៃអស់អ្នកដែលរស់នៅក្នុងពិភពលោកដែលមិន ជឿលើអទិទេព។ ដាវីឌ និងមីស្សែល បានដឹងពីមាត្រានៃសេចក្ដីជំនឿនេះតាំងពីយូរមកហើយ តាំងពីមុនពេលគេស្គាល់ គ្នា។ ទោះជាដូច្នេះក៏ដោយ ពួកគេប្រឈមមុខនឹងចម្ងល់ជាច្រើនដូចមនុស្ស ដែលបានចូលរួមក្នុងការចាក់ផ្សាយនេះដែរ។ អ្នកឃើញទេ ដាវីឌ និងមីស្សែល មានអាយុជាងម្ភៃឆ្នាំប៉ុណ្ណោះ។ ពួកគេបានស្គាល់គ្នាដោយចៃដន្យ ពួកគេ “ដើរលេង” ជាមួយគ្នា ហើយពួកគេស្រឡាញ់គ្នា។ ទោះជាយ៉ាងណាក្ដី ពួកគេមិនទាន់សម្រេចចិត្តអំពីអាពាហ៍ពិពាហ៍ និងសាងគ្រួសារ នៅឡើយទេ។ តើពួកគេគួរតែពន្យាពេលរៀបអាពាហ៍ពិពាហ៍រហូតដល់ពេលពួកគេបញ្ចប់ការសិក្សា មានលុយច្រើនជាងនេះ និងរហូតដល់មហិច្ឆិតាផ្ទាល់ខ្លួនរបស់ពួកគេបានសំរេចឬ?

ពួកគេមានមន្ទិលយ៉ាងខ្លាំងអំពីនិន្នាការនៃការលែងលះ សង្គ្រាមច្របូកច្របល់នៅជុំវិញពិភពលោក ហើយកំណើនលើសលុបនៃប្រជាពលរដ្ឋ។ តើអាពាហ៍ពិពាហ៍របស់ពួកគេអាចរស់រានមានជីវិតឬទេ? តើពួកគេគួរតែនាំកូនចៅមកក្នុងពិភពលោកដូច្នេះឬទេ?

ចូរចាំ ដាវីឌ និងមីស្សែល ចូរអនុវត្តន៍សេចក្ដីជំនឿរបស់អ្នក!ៈ “អាពាហ៍ពិពាហ៍រវាងបុរស និងស្ត្រី គឺតែងតាំងឡើងដោយព្រះ។” [16] “យ៉ាងនោះ...កុំឱ្យអ្នកពង្រាត់មនុស្សដែលព្រះបានផ្សំផ្គុំឡើយ។ ” (ម៉ាថាយ 19:6 សូមមើល ផងដែរ 132:19–20)។ “មើលកូនចៅជាមរដកមកពីព្រះយេហូវ៉ា។ ” (ទំនុកដំកើង 127:3)។ “ត្បិតផែនដីបានពោរពេញ...ហើយមានបរិបូរណ៍គ្រប់គ្រាន់” (សូមមើល គ និង ស 140:17)។

ធ្វើសកម្មភាពទៅតាមអ្វីដែលអ្នកជឿថាពិត និងប្រព្រឹត្តិតាមសេចក្ដីសុចរិត ដែលធ្វើឱ្យសេចក្ដីជំនឿរបស់អ្នកបានឥតខ្ចោះ។ នោះជីវិតរបស់អ្នកនឹងបានពេញលេញ ហើយអស្ចារ្យ។ ចូរធ្វើតាមគំរូដ៏ល្អរបស់ឪពុកម្ដាយអ្នក។ ពួកគាត់ គ្មានលុយគ្រប់គ្រាន់ដើម្បីរៀបអាហ៍ពិពាហ៍ ប៉ុន្តែពួកគាត់បានធ្វើ។ ហើយពួកគាត់ក៏មានការព្រួយបារម្ភអំពីសង្គ្រាម



© 2006 ដោយ Intellectual Reserve, Inc។ រក្សាសិទ្ធិគ្រប់យ៉ាង។ បោះពុម្ពនៅព្រះរាជាណាចក្រកម្ពុជា។ អនុមតិជាភាសាអង់គ្លេសៈ 6/05។ 00942 258

និង ភាពចលាចលដែរ ប៉ុន្តែពួកគាត់បានអនុវត្តន៍សេចក្តីជំនឿ ហើយអ្នកក៏ត្រូវធ្វើដូច្នេះដែរ! ការទាមទារឱ្យរៀបអាពាហ៍ពិពាហ៍ និងសាងគ្រួសារគឺមិនបង្អាក់ដល់ការអប់រំរបស់ពួកគាត់ទេ តែពួកគាត់កាន់តែធ្វើឱ្យមានខ្លឹមសារបន្ថែមទៀត។ ចំពោះមហិច្ឆតាផ្ទាល់ខ្លួនពួកគាត់អាចទទួលបានជោគជ័យ និងរីករាយជាមួយគ្នា និងជាមួយអ្នក បងប្អូនប្រុសស្រីរបស់អ្នក និងចៅរបស់អ្នក។

ជីវិតមិនមែនជាការងាយស្រួលទេ សំរាប់ឪពុកម្តាយរបស់អ្នក។ ពួកគាត់ត្រូវសន្សំសំចៃរស់នៅតាមអ្វីដែលពួកគេ មាន។ ពួកគេក៏បានប្រឈមមុខនឹងសំណួរ និងស្ថានភាពដែលពួកគាត់មិនអាចរកចំលើយបាន ប៉ុន្តែពួកគាត់ស្គាល់ផ្លូវ ដែលបានតែងតាំងដោយព្រះដ៏មានមហិទ្ធិឫទ្ធិ ដែលពួកគេអាចឆ្ពោះទៅមុខ។ ហើយអ្នកកាន់តែ "មាន" ច្រើនជាង ពួកគាត់ ទៅទៀតពីព្រោះតែសេចក្តីជំនឿវា។

ចេញពីរឿងរ៉ាវទាំងឡាយដែលពួកគេបានប្រាប់ម្តងហើយម្តងទៀត អ្នកបានដឹងអ្វីៗគ្រប់យ៉ាង "ទាំងពីរផ្លូវ។ " ប៉ុន្តែការប្រព្រឹត្តតាមរបស់ពួកគាត់ បានធ្វើឱ្យសេចក្តីជំនឿពួកគាត់បានបរិសុទ្ធ។

ពួកគាត់កាន់តែចាស់ ប្រាកដណាស់ ជំហានពួកគាត់មិនរហ័សរហួន របៀបរបបរបស់ពួកគាត់មិនគួរឱ្យចាប់អារម្មណ៍ទៀត ទេ រូបរាងរបស់ពួកគាត់ពេលខ្លះមិនលេចធ្លោ មិនអ៊ូអរ។ ប៉ុន្តែសេចក្តីស្រឡាញ់របស់ពួកគេចំពោះព្រះ និងចំពោះគ្នាទៅ វិញទៅមក មានឥទ្ធិពលដោយគារវភាពយ៉ាងជ្រាលជ្រៅ និងគួរឱ្យកោតសសើរ។ ស្នាកស្នាមដែលពួកគាត់មានក្នុងជីវិត ធ្វើឱ្យពួកគាត់មានប្រាជ្ញា ការអត់ធ្មត់ និងគារវភាព។ តាមរយៈវិធីតូចតាច តែសំខាន់ ពួកគាត់បានប្រែក្លាយទៅជា "ចិត្ត ដែលដឹងជាក់ថានឹងបានដូចសង្ឃឹម ជាទីសំគាល់ពីការដែលមើលមិនឃើញ" (ហេព្រើរ 11:1) —អ្វីដែលពួកគាត់មើល មិនឃើញកាលពីនៅវ័យក្មេងក្នុងជីវិត។ តែពួកគាត់គោរពប្រតិបត្តិ។ អនុវត្តន៍សេចក្តីជំនឿរបស់ពួកគាត់ ពួកគាត់ផ្សា ភ្ជាប់ក្នុងព្រះវិហារបរិសុទ្ធ បានទទួលពរជ័យជាមានកូនៗ ហើយបច្ចុប្បន្ននេះបានដឹងពីប្រភពនៃសុភមង្គលពិតប្រាកដ។ *បទដ្ឋានដែលបង្ហាញពីៈ ការគោរពប្រតិបត្តិ នាំមកនូវពរជ័យពីស្ថានសួគ៌—វាកើតឡើងចំពោះឪពុកម្តាយរបស់អ្នក វាក៏នឹងកើត ឡើងចំពោះអ្នកដូច្នេះដែរ។*

## ការបំរើដែលយើងផ្តល់ឱ្យ

*ទីបួន បទដ្ឋាននៃការបំរើ។* ពួកបរិសុទ្ធថ្ងៃចុងក្រោយ—"ជឿដល់ព្រះ គឺជាព្រះវរបិតាដ៏គង់នៅអស់កល្បជានិច្ច និងដល់ ព្រះរាជបុត្រាទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ ហើយដល់ព្រះវិញ្ញាណបរិសុទ្ធ...។

យើងខ្ញុំជឿ...ថាព្រះគ្រីស្ទនឹងសោយរាជ្យនៅលើផែនដីផ្ទាល់ ហើយថាផែនដី នឹងបានផ្លាស់ប្តូរសារជាថ្មី ហើយនឹងទទួលសិរីល្អដ៏ប្រកបដោយភាពបរមសុខ។ " (មាត្រានៃសេចក្តីជំនឿ 1:1, 10)។

យើងដឹងកាន់តែច្រើនពីក្រុមព្រះទាំងបីអង្គ នោះគំនិតរបស់មនុស្សទាំងអស់នឹងយល់ច្បាស់ពីការចាប់ផ្តើម—អ្វីដែល យើងដឹងគឺជាការពិត។ បន្ថែមពីលើនេះទៀត យើងដឹងពីគោលបំណងរបស់ព្រះអទិទេព ចំពោះផែនដីនេះ និងការ បង្កបង្កើតទាំងឡាយ។ ដោយសារតែអ្វីដែលយើងបានដឹង ហើយពីព្រោះតែព្រះអម្ចាស់បានដាក់លើស្មារបស់យើងនូវភារកិច្ចពិសិដ្ឋ ឱ្យជួយកិច្ចការនេះទៅមុខ យើងមិនត្រូវមិនខ្វល់ពីភាពជាសមាជិករបស់យើងនៅក្នុងសាសនាចក្រនោះទេ។

មនុស្សមួយចំនួនត្រូវទទួលរងនូវការល្បួង ចាប់ផ្តើមមិនធ្វើការប្តេជ្ញាចិត្ត ដោយខ្លាចថាហាក់បីដូចប្រាកដឡើងជាអ្នកសាសនានិមយពេក។ ទស្សនះរបស់ពួកគេគឺ "សាសនាចក្រគឺជាស្ថាប័នមួយ ប៉ុន្តែមិនមែនជានគរឡើយ។" [17] "អូ៎! យុវជនដែលថ្លៃថ្នូរដែលសិទ្ធិមានតាំងពីកំណើតអើយ" [18] ចូរធ្វើឱ្យកិច្ចការរបស់សាសនាចក្រ និងនគរព្រះចូលមកក្នុងជីវិតរបស់អ្នក។ នៅពេលដែលត្រូវបានហៅឱ្យបំរើ ចូរនិយាយពាក្យថា "ព្រម" ហើយខំធ្វើឱ្យអស់ពីលទ្ធភាពរបស់អ្នក។ ចូរស្តាប់តាមច្បាប់ដែលមកពីព្រះអម្ចាស់ៈ "ហេតុដូច្នេះហើយ កុំស្វែងរកវត្ថុក្នុងលោកិយនេះឡើយ តែស្វែងរកទ្រង់ជាមុន ដើម្បីស្ថាបនានគររបស់ព្រះ ហើយស្ថាបនានៅលើសេចក្តីសុចរិតរបស់ទ្រង់ នោះអ្វីៗគ្រប់យ៉ាងនឹងប្រទានឱ្យអ្នក។ " (JST ម៉ាថាយ 6:38)។

បួនថ្ងៃទៀតនៅថ្ងៃទី 9 ខែ វិច្ឆិកា គឺមានរយៈពេល 150 ឆ្នាំហើយចាប់តាំងពីមានរឿងអកុសលនៃអ្នកត្រួសត្រាយផ្លូវ ក្រុមរទេះរុញ វីលី ដែលជួបប្រទះភាពស្មុគស្មាញក្នុងការធ្វើដំណើរទៅជ្រលងភ្នំ សលត៍ លេក។ ពួកគេដើរឆ្លងទឹក រងទុក្ខ និងសេចក្តីស្លាប់។ ខ្យល់ព្យុះ និងស្ថានភាពទន់ខ្សោយរបស់ពួកគេ បានធ្វើឱ្យពួកគេជួបគ្រោះមហន្តរាយ—ហើយក្រុមជួយសង្គ្រោះក៏បានសង្គ្រោះជីវិតច្រើនដែរ។

លេវី ស៊ែវេច ក៏ជាមនុស្សម្នាក់ក្នុងចំណោមពួកគេដែលបានមកដល់នៅថ្ងៃនោះផងដែរ។ ប្រវត្តិសាស្រ្តបានកត់ត្រាទុក ពីភាពស្មោះត្រង់ និងឆន្ទះមោះមុត ក្នុងការជួយសង្គ្រោះដល់ពួកបរិសុទ្ធ ហើយនាំគេមកជ្រលងភ្នំដោយសុវត្ថិភាព។ តែការបំរើដ៏ថ្លៃថ្នូររបស់គាត់មិនបានចាប់ផ្តើមឡើងនៅទីវាលទឹកកក នៃទីក្រុង វ៉ាយអូមីង ទេ។ កិច្ចការទាំងនោះបានធ្វើពិតមែន តែគឺនៅក្នុងជំពូកផ្សេង ប្រហែលនេះគឺជាការបំរើមួយដ៏ពិតប្រាកដ ក្នុងការបំរើជួយដល់ជីវិតដ៏ពិសិដ្ឋ។

លេវី បានទទួលពិធីបុណ្យជ្រមុជទឹកនៅខែ មិថុនា ឆ្នាំ 1846 កាលអាយុ 26 ឆ្នាំ។ ដែលបានឆ្លើយតបនឹងការហៅរបស់ព្យាការីឱ្យផ្លាស់ទីលំនៅទៅភាគខាងលិច គាត់បានកត់ត្រាថាៈ "យើងបានត្រៀមខ្លួនឱ្យបានល្អបំផុតតាមដែលអាចធ្វេទៅបានដើម្បីធ្វើដំណើរវែងឆ្ងាយទៅកន្លែងដ៏ចម្លែក ហើយចំពោះយើងគឺមិនដឹងអ្វីទាល់តែសោះពីទីក្រុងថ្មីនោះ... យើងនិយាយពាក្យថាលាហើយ ទៅកាន់ស្រុកកំណើតរបស់យើង...ហើយធ្វើដំណើរសំដៅទៅភាគខាងលិច មិនទាំងស្គាល់ទីកន្លែង ដែលសំដៅទៅនោះផង យើងគ្រាន់តែរំពឹងថាគឺបោះទីតាំងនៅកន្លែងណាមួយនៅទីវាលភាគខាងលិចនៃភ្នំ រ៉ក់គី។ " [19]

នៅថ្ងៃទី 16 ខែកក្កដា ឆ្នាំ 1846 គាត់នឹងបុរសក្លាហានផ្សេងៗទៀត បានឆ្លើយតបនឹងការហៅរបស់ព្យាការីជាបន្ទាន់ ជាថ្មីឱ្យចូលរួមនៅក្នុងកងទ័ពមរមន ហើយដើរក្បួនប្រហែល 3200 គីឡូម៉ែត្រ ពី ខោនស៊ីល ប៊ុលហ្វ អាយអូវ៉ា ទៅ សានឌីអាហ្គោ រដ្ឋកាលីហ្វ័រនីញ៉ា បន្ទាប់មកទៅ ឡូស អានជែលែ។ នៅទីនោះ ពួកគេត្រូវបានបណ្តេញចេញពីការបំរើរបស់រដ្ឋាភិបាល។ ថ្វីបើពួកគេមិនបានដឹងអ្វីទាល់តែសោះថាត្រូវឈប់នៅទីណាដើម្បីតាំងទីលំនៅ និងសាងគ្រួសារពួកគេក៏ដោយ ក៏ពួកគេនៅតែចាប់ផ្តើមបរទេះទៅជ្រលងភ្នំ ហ្គ្រេត សលត៍ លេក ដែរ។ ផ្លូវដែល លេវី ស៊ែវេច ធ្វើដំណើរមានចំងាយ 2100 គីឡូម៉ែត្រ ឆ្លងកាត់ព្រៃភ្នំ តែនៅទីបំផុតគាត់បានធ្វើដំណើរមកដល់ជ្រលងភ្នំ សលត៍ លេក។



© 2006 ដោយ Intellectual Reserve, Inc។ រក្សាសិទ្ធិគ្រប់យ៉ាង។ បោះពុម្ពនៅព្រះរាជាណាចក្រកម្ពុជា។ អនុមតិជាភាសាអង់គ្លេសៈ 6/05។ 00942 258

នៅទីនេះពួកអ្នកត្រួសត្រាយផ្លូវ លេរី បានស៊ូទ្រាំនឹងការពិបាក បានរៀបការមានកូនប្រុសម្នាក់ ហើយភរិយារបស់គាត់បានទទួលមរណភាពបន្ទាប់ពីឆ្លងទន្លេ។ ដប់ខែក្រោយមកបន្ទាប់ពីមរណភាពរបស់ភរិយាគាត់ នៅក្នុងសន្និសីទ ខែ តុលា ឆ្នាំ 1852 គាត់ និងបងប្អូនប្រុសដ៏ស្មោះត្រង់ជាច្រើននាក់ទៀតត្រូវបានហៅដោយព្យាការីឱ្យបើកបេសកកម្មដំណឹងល្អនៅប្រទេសសៀម (បច្ចុប្បន្ននេះហៅថា ប្រទេសថៃ)។

លើកនេះពួកគេបានធ្វើដំណើរជាក្រុម ហើយធ្វើដំណើរដោយរទេះកង់បួនចុះមកតាមឆ្នេរសមុទ្ររដ្ឋកាលីហ្វ័រញ៉ា និង មហាសមុទ្រ ប៉ាស៊ីហ្វិក។ នៅពេលនោះពួកគេធ្វើដំណើតាមនាវាពី សាន់ប្រាហ៊ាន់ ស៊ីស្កូរ ទៅ កាគូតា ឆ្ពោះទៅបេសកកម្មរបស់ពួកគេនៅប្រទេសសៀម។ ក្នុងសៀវភៅកំណត់ហេតុរបស់ លេរី សរសេរនៅថ្ងៃទី 29 ខែ កុម្ភៈ ឆ្នាំ 1853 បានផ្ដល់ដល់យើងនូវពន្លឺបន្តិចបន្តួចឱ្យមើលឃើញពីទឹកចិត្តអ្នកផ្សព្វផ្សាយសាសនាពីជំនាន់មុន។ គាត់បានសរសេរថាៈ

“កប៉ាល់ដ៏ធំរបស់យើង ធ្វើដំណើរទៅមុខដោយខ្យល់បកទៅមុខសន្សឹមៗ ឆ្លងកាត់រលកបោកបក់ធំៗចេញពលំនៅរបស់យើងឆ្ពោះទៅមុខ ទុកចោលមាតុភូមិជាទីស្រឡាញ់របស់យើងមួយឡែក...ម្នាក់ៗស្វែងរកកន្លែងស្ងប់ស្ងាត់រៀងៗខ្លួន ហើយគិតពីគេហដ្ឋានដ៏កក់ក្ដៅរបស់ពួកគេ ពីមនោសញ្ចេតនាចំពោះ ភរិយា កូនចៅ និងមិត្តជាទីស្រឡាញ់របស់ពួកគេ...។ ប៉ុន្តែពេលនេះគាត់ត្រូវបានហៅឱ្យផ្លាស់ទៅតំបន់ដាច់ស្រយាលម្ខាងទៀតនៃផែនដី ដើម្បីអ្វីទៅ? ដើម្បីជីករកមាស ប្រាក់ ឬដើម្បីការពារកិត្តិយសគ្រួសារ កិត្យានុភាព និង ឧត្តមភាព នៃពិភពលោកនេះឬ? *ទេ ពិតជាមិនមែនទេ! ប៉ុន្តែដោយសារការប្រតិបត្តិតាមបញ្ញត្តិរបសព្រះអម្ចាស់ ដើម្បីពាំនាំសារលិខិតនៃសេចក្ដីពិតនិង...ផែនការនៃសេចក្ដីសង្គ្រោះដល់ជាតិសាសន៍ដែលស្ថិតក្នុងទីងងឹត និងជំនឿ ឆ្វេង។* “មិនយូរប៉ុន្មាន ម្នាក់ៗបានសំរាកលើប៉ោអ៊ីដើម្បីយកកំលាំង និងធ្វើដំណើរទៀត ។ ប៉ុន្តែមិនថាគេងលក់ ឬដឹងខ្លួននោះទេ ក្នុងគំនិតរបស់គាត់នៅបន្តងឿងឆ្ងល់អំពីរឿងរ៉ាវជាក់ស្តែង នៅអតីតកាល និងការរំពឹងទុកនាពេលអនាគត។” [20]

បន្ទាប់ពីបេសកកម្មរបស់គាត់ លេរី បានបើកនាវាមកផ្ទះតាមទីក្រុងបូស្តុន ម៉ាសាជូសែតនៅតាមផ្លូវស្រុកកំណើតរបសគាត់នៅ គ្រីនហ្វៀល អូហៃអូ ហើយបានសរសេរចុះពីការមកដល់នៅទីនោះថាៈ “ខ្ញុំបានធ្វើដំណើរជុំវិញផែនដី។” [21] គាត់បានចូលរួមធ្វើដំណើរជាមួយក្រុមរទេះរុញ វីលី នៅទីក្រុង អៃអូវ៉ា ដែលជាដំណើររឿងមួយយ៉ាងសំខាន់ចំពោះគាត់ ចំពោះក្រុមគ្រួសារគាត់ និងចំពោះសាសនាចក្រទាំងមូល។ កិច្ចការរបស់គាត់នៅក្នុងដំណើររឿងនៃជីវិតពលិកម្មដ៏កំពូល និងការបំរើ។ ប្រាកដណាស់អ្នកត្រួសត្រាយផ្លូវទាំងនោះគឺជ *បង្ហាញពីចំណុចគោល ៈ នៃសេចក្ដីជំនឿ និងការប្រព្រឹត្តតាមពួកគេ គឺជាភ្លើងសញ្ញានាំផ្លូវនៅក្នុងពិលោកដែលមិនជឿ ការបំរើរបស់ពួកគេគឺសំរាប់ឱ្យយើងធ្វើតាម។*

យើងបានធ្វើដំណើរឆ្ពោះទៅមុខដោយសារពាក្យពេចន៍ មកពីបព្វជិតម្នាក់ឈ្មោះ ហ្វីឌីរីក ដុបិលយូ ហ្វាបរ័ ថាៈ

*“ជំនឿនៃជីដូនជីតារបស់យើង រស់នៅជានិច្ច*
*ទោះជានៅក្នុងគុកងងឹត ក្នុងភ្លើង និងមុខដាវក្ដី*
*ដួងចិត្តយើងរីករាយខ្លាំងណាស់*
*ពេលយើងឮ ព្រះបន្ទូលដ៏ឧត្ដម។*

*ជំនឿនៃជីដូនជីតារបស់យើង យើងនឹងខិតខំ*
*ដើម្បីយកឈ្នះលើជាតិសាសន៍ទាំងអស់ឱ្យមករកទ្រង់*
*និងសេចក្ដីពិតដែលមកពីព្រះ*
*មនុស្សលោកទាំងអស់ នឹងមានសេរីភាពពិតប្រាកដ។*

*ជំនឿនៃជីដូនជីតារបស់យើង ជាមួយក្ដីស្រឡាញ់*
*ទាំងមិត្ត និងសត្រូវ យើងស៊ូទាំងអស់*
*ហើយប្រកាសពីទ្រង់ ឱ្យស្គាល់ពីក្ដីស្រឡាញ់*
*តាមរយៈបន្ទូលផ្អែមល្ហែម និងជីវិតមានគុណធម៌។*

*ជំនឿនៃជីដូនជីតារបស់យើង ជាជំនឿ ទាំងស្រុង*
*ដែលយើងត្រូវតែនៅពិត រហូតដល់ស្លាប់!”* [22]

បងប្អូនប្រុសស្រីជាទីស្រឡាញ់របស់ខ្ញុំ ខ្ញុំសូមថ្លែងជាសាក្សីថា— ព្រះគង់នៅក្នុងស្ថានសួគ៌របស់ទ្រង់ ព្រះនាមទ្រង់គឺ អេឡូហិម ហើយទ្រង់ស្គាល់កូនចៅរបស់ទ្រង់ទាំងអស់ ដោយមិនគិតថាពួកគេមកនៅពេលណា ឬរស់នៅកន្លែងណាទេ។ ព្រះយេស៊ូវដែលជាព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល គឺជាព្រះបុត្រាសំណប់របស់ទ្រង់ព្រះប្រោសលោះរបស់មនុស្សលោក។ យ៉ូសែប ស៊្មីធ ដែលជាក្មេងប្រុសម្នាក់ ត្រូវបានហៅដោយសំឡេងរបស់ព្រះ និងព្រះរាជបុត្រាដ៏បរិសុទ្ធរបស់ទ្រង់ ឱ្យធ្វើជាព្យាការី ហើយផលមកពីការហៅនោះ គឺជាសាសនាចក្រពិត និងនគររបស់ព្រះ ត្រូវបានស្ដារឡើងវិញនៅលើផែនដី។ តើនេះជាពរជ័យប៉ុណ្ណា ដើម្បីចេះដឹងរឿងទាំងអស់នេះ ហើយអ្នករាល់គ្នា បងប្អូនប្រុសស្រីជាទីស្រឡាញ់របស់ខ្ញុំ អ្នកឈរនៅលើចំណុចប្រសព្វនៃប្រវត្តិសាស្ត្រ។ អ្នកមកពីនគរដ៏រុងរឿង។ វាគឺជាសិទ្ធផ្ទាល់ខ្លួនរបស់អ្នកក្នុងការនៅតែពិតចំពោះសេចក្ដីជំនឿ ដើម្បីឆ្ពោះទៅមុខនៅក្នុងកិច្ចការល្អ។ សូមធ្វើតាមអ្វីដែលព្យាការីមានប្រសាសន៍។ ជំនាន់ពីមុនៗ សង្ឃឹមលើយើង ហើយជំនាន់ក្រោយពឹងផ្អែកលើវា ហើយព្រះវិញ្ញាណបរិសុទ្ធនឹងដឹកនាំអ្នកគ្រប់ជំហាននៅតាមផ្លូវ។

នៅក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ អាម៉ែន។

## កំណត់ចំណាំ


1. “យើងសូមអរគុណព្រះអង្គចំពោះព្យាការី” *ទំនុកដំកើងព្រះ និងចំរៀងកុមារាកុមារី* ទំព័ 36 ។

2. នៅក្នុង Conference Report ខែតុលា ឆ្នាំ 2006, 87 ឬ *Ensign* ខែ វិច្ឆិកា ឆ្នាំ 2006, 82 អក្សរទ្រេតគឺជា ការបន្ថែម។

3. *Random House Webster’s Unabridged Dictionary,* 2nd ed. (2001), “secular,” 1731 ។

4. Alexander Pope, *An Essay on Man,* epistle 2, line 220។

5. *Book of Mormon Reference Companion*, ed. Dennis L. Largey, បោះពុម្ពផ្សាយ ( 2003) 582 ។




© 2006 ដោយ Intellectual Reserve, Inc។ រក្សាសិទ្ធិគ្រប់យ៉ាង។ បោះពុម្ពនៅព្រះរាជាណាចក្រកម្ពុជា។ អនុមតិជាភាសាអង់គ្លេសៈ 6/05។ 00942 258

6. "How to Think about Secularism," *First Things* June–July 1996, 27–30។ www.firstthing.com/ftissues/ft9606/articles/pannenberg.html។

7. ផាកកឺ ជាអ្នកដឹកនាំទូទៅ ខែតុលា ឆ្នាំ 2006 សូមមើលផងដែរ William Shakespeare, *The Tempest*, ed. W. J. Craig, Oxford Shakespeare (1924), act 2, scene 1, line 261។

8. នៅក្នុង *Conference Report*, Apr. 1991, 74 or *Ensign*, May 1991, 54។

9. នៅក្នុង Conference Report ខែកញ្ញា—តុលា ឆ្នាំ 2006, 90, ឬ *Ensign*, Nov. 2006, 85។

10. យ៉ូសែបស្ម៊ីធ comp *Lectures of Faith* (1985) 5, 8។

11. *Random House Webster's Unabridged Dictionary*, "benchmark," 193។

12. នៅក្នុង Conference Report ខែកញ្ញា—តុលា ឆ្នាំ 2006, 66 ឬ *Ensign*, Nov. 2006, 60។

13. សូមមើលផងដែរ ប៊ិយឃេ ផាកកឺ *Memorable Stories and Parables of Boyd K. Packer* (1997) 4–6។

14. "មក មកពួកបរិសុទ្ធ" *ទំនុកដំកើង* ទំព័រ 2។

15. "Carry On," *Hymns*, no. 255។

16. "ក្រុមគ្រួសារ— សេចក្តីប្រកាសដល់ពិភពលោក។" *Ensign*, Nov. 1995, 102។

17. ឡៀល អេ ម៉ាក់ស្វែល នៅក្នុង *Conference Report*, Oct. 1992, 89; or *Ensign*, Nov. 1992, 66។

18. "Carry On," *Hymns*, no. 255។

19. នៅក្នុង Levi Savage Jr. Journal, comp. Lynn M. Hilton (1966) xii.។

20. នៅក្នុង *Levi Savage Jr. Journal 5*អក្សរទ្រេតគឺជាការបន្ថែម។

21. នៅក្នុង *Levi Savage Jr. Journa, 59*។

22. "Faith of Our Fathers," *Hymns*, no. 84។



© 2006 ដោយ Intellectual Reserve, Inc។ រក្សាសិទ្ធិគ្រប់យ៉ាង។ បោះពុម្ពនៅព្រះរាជាណាចក្រកម្ពុជា។ អនុមតិជាភាសាអង់គ្លេសៈ 6/05។ 00942 258